Australian Government
Department of Education, Skills and Employment

Disability Standards for Education 2020 Review

**ការពិនិត្យឆ្នាំ ២០២០ នៃ *ស្តង់ដារជនពិការសម្រាប់ការអប់រំឆ្នាំ ២០០៥***

# ក្រដាសពិភាក្សា: កុមារដែលមានពិការភាពដែលស្ថិតនៅក្នុងការអប់រំកុមារតូចៗ និងការថែទាំ

## សេចក្តីផ្តើម

គោលបំណងនៃឯកសារពិភាក្សានេះគឺដើម្បីគាំទ្រដល់ការពិគ្រោះយោបល់របស់រាជរដ្ឋាភិបាលអូស្ត្រាលីទាក់ទងនឹងការអប់រំ និងការថែរក្សាកុមារតូចៗសម្រាប់ការត្រួតពិនិត្យឡើងវិញ (ការពិនិត្យឡើងវិញ) ឆ្នាំ២០២០ នៃ*ស្តង់ដារជនពិការសម្រាប់ការអប់រំឆ្នាំ២០០៥* (បទដ្ឋាន) ។ នេះត្រូវធ្វើតាមក្រោយពីអត្ថបទពិភាក្សាលើកដំបូងដែលបានចេញផ្សាយនៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ ២០២០ ដែលបានថែងអំពីតួនាទីនៃបទដ្ឋាន និងគោលបំណង និងវិសាលភាពនៃការពិនិត្យឡើងវិញ។

នៅក្នុងឯកសារនេះយើងបានបង្ហាញពីរបៀបដែល *ច្បាប់ស្តីពីការរើសអើងជនពិការឆ្នាំ១៩៩២* និងបទដ្ឋានអនុវត្តចំពោះការអប់រំ និងការថែទាំកុមារតូចៗ។ យើងនឹងពន្យល់នូវអ្វីដែលការពិនិត្យពីមុនបានប្រាប់យើងអំពីការអប់រំ និងការថែរក្សាកុមារតូចៗ និងបទដ្ឋានអ្វីដែលយើងចង់សិក្សារៀនសូត្រមកវិញនៅក្នុងការពិនិត្យឡើងវិញនេះ និងវិធីដែលលោកអ្នកអាចចូលរួមជាមតិយោបល់។ ឯកសារនេះក៏រួមបញ្ចូលនូវសំណួរពិភាក្សាដើម្បីជួយយើងឱ្យស្វែងយល់អំពីទស្សនៈ និងបទពិសោធន៍របស់លោកអ្នក។

មានភស្តុតាងជាក់ស្តែងដែលបានឱ្យយើងដឹងថា**ឆ្នាំដំបូងនៃជីវិតរបស់កុមារមានឥទ្ធិពលយ៉ាងខ្លាំងទៅលើការអភិវឌ្ឍនៃខួរក្បាល, សង្គម, ការគិត, ផ្លូវចិត្ត និងរាងកាយនាពេលអនាគត**។ ជំនាញនិងសមត្ថភាពដែលទទួលបានក្នុងវ័យកុមារភាពគឺជាមូលដ្ឋានគ្រឹះនៃភាពជោគជ័យ និងសុខុមាលភាពរបស់ពួកគាត់នៅពេលក្រោយ។

ការអប់រំ និងការថែរក្សាកុមារតូចៗផ្តល់ជាមូលដ្ឋានសម្រាប់កុមារឱ្យរៀន និងអភិវឌ្ឍនៅក្នុងបរិស្ថានដែលមានសុវត្ថិភាពខណ:ពេលដែលពួកគេក៏មានឱកាសដើម្បីទំនាក់ទំនងសង្គមជាមួយកុមារដទៃៗទៀតដែរ។ ក្រៅពីផ្តល់អត្ថប្រយោជន៍ដល់ការអភិវឌ្ឍកុមារការអប់រំ និងការថែរក្សាកុមារតូចៗក៏បានជួយដល់ក្រុមគ្រួសារដែលកំពុងធ្វើការវិលត្រឡប់មកធ្វើការវិញដែរ។

នៅក្នុងត្រីមាសខែធ្នូ ឆ្នាំ២០១៩ កុមារ ១,៣លាននាក់មកពីជាង ៩០០.០០០ គ្រួសារបានចូលរួមក្នុងសេវាថែទាំ និងថែទាំកុមារតូចៗ។ នៅឆ្នាំ២០១៨ ការិយាល័យស្ទង់មតិស្ថិតិអូស្ត្រាលីស្តីពីជនពិការ វ័យចំណាស់ និងអ្នកថែទាំ (SDAC) បានរាយការណ៍ថា**កុមារអាយុ ០ ដល់ ៤ឆ្នាំចំនួន ០៤ភាគរយមានពិការភាព។**

## *ច្បាប់ស្តីពីការរើសអើងជនពិការឆ្នាំ១៩៩២* និងការអប់រំ និងការថែទាំកុមារតូចៗ

**ច្បាប់ស្តីពីការរើសអើងជនពិការឆ្នាំ ១៩៩២ (DDA) គឺជាច្បាប់ដែលត្រូវបានអនុវត្តអស់រយៈពេលជិត ៣ ទសវត្សមកហើយ។**

នៅក្រោម DDA, វាជា**ការខុសច្បាប់ក្នុងការរើសអើងមនុស្សម្នាក់ដោយឈរលើមូលដ្ឋាននៃពិការភាព**។ DDA ការពារជនពិការប្រឆាំងនឹងការរើសអើងនៅក្នុងវិស័យជាច្រើននៃជីវិតសាធារណ:រួមទាំងការអប់រំ។

**រាល់សេវាកម្មថែទាំ និងការអប់រំកុមារតូចត្រូវតែគោរពតាម** DDA ។

យោងតាម**មាត្រា២២ នៃ DDA** វាជារឿងខុសច្បាប់សម្រាប់អាជ្ញាធរអប់រំក្នុងការបដិសេធ ឬ ខកខានមិនទទួលយកពាក្យសុំរបស់មនុស្សសម្រាប់ការចូលរៀន ឬ ដើម្បីធ្វើឱ្យមានលក្ខខណ្ឌជាក់លាក់ណាមួយនៅលើការទទួលយក ដែលរើសអើងបុគ្គលនោះដោយផ្អែកលើមូលដ្ឋាននៃពិការភាពរបស់ពួកគេ។ វាជាការខុសច្បាប់ផងដែរសម្រាប់អ្នកផ្តល់ការអប់រំក្នុងការរើសអើងមនុស្សម្នាក់ដោយផ្អែកលើមូលដ្ឋាននៃពិការភាពរបស់ពួកគេរួមទាំងកម្មវិធីសិក្សាដែលធ្វើឱ្យមានការវិបាកក្នុងការចូលរួមសកម្មភាពទាំងនោះដោយហេតុបុគ្គលចូលរួមនោះមានពិការភាព។

ប្រសិនបើអ្នកផ្តល់ការអប់រំ និងថែទាំកុមារតូចមិនត្រូវបានគេចាត់ទុកថាជាអាជ្ញាធរអប់រំ ឬ អ្នកផ្តល់ការអប់រំដូចដែលបានកំណត់នៅក្នុងDDAនោះ ពួកគេចាំបាច់ត្រូវគោរពតាម**មាត្រា២៤ នៃ DDA** វាជារឿងខុសច្បាប់ប្រសិនបើអ្នកលក់ទំនិញ សេវាកម្ម ឬ គ្រឿងបរិក្ខារនានាបដិសេធមិនផ្តល់ទំនិញ សេវាកម្ម ឬ គ្រឿងបរិក្ខារទាំងនោះដល់នរណាម្នាក់ដោយសារតែភាពពិការរបស់ពួកគេ។ នេះរួមបញ្ចូលទាំងលក្ខខណ្ឌពីរបៀបដែលទិញទំនិញ ឬ សេវាកម្ម។

នៅក្រោម DDA អ្នកផ្តល់ការអប់រំ និងថែទាំកុមារតូច**ត្រូវធ្វើការកែតម្រូវសមហេតុផល**ដើម្បីសម្រួលឱ្យមានភាពងាយស្រួលក្នុងការទទួលបានសេវាកម្មនានាពីជនដែលមានពិការភាព មានករណីលើកលែងប្រសិនបើការកែសម្រួលនោះបង្កការលំបាកដល់អ្នកផ្តល់សេវាកម្ម។

## បទដ្ឋានពិការភាពសម្រាប់ការអប់រំ និងការអប់រំព្រមទាំងការថែទាំកុមារតូចៗ

***ស្តង់ដារជនពិការសម្រាប់ការអប់រំឆ្នាំ២០០៥*** (បទដ្ឋាន) បានចូលជាធរមាននៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៥ ។ ច្បាប់នេះមានគោលបំណងដើម្បីធានាថាសិស្សដែលមានពិការភាព**អាចរួមក្នុងការអប់រំដោយផ្អែកលើមូលដ្ឋានដូចគ្នានឹងសិស្សដែលគ្មានពិការភាព។**

បទដ្ឋាននេះគឺជាច្បាប់បន្ទាប់បន្សំចំពោះ DDA ។ នេះមានន័យថាបទដ្ឋាននេះស្ថិតនៅក្រោម DDA ។ គោលបំណងនៃបទដ្ឋាននេះគឺដើម្បីបញ្ជាក់ពីកាតព្វកិច្ចរបស់អ្នកផ្តល់ការអប់រំ និង បណ្តុះបណ្តាល និងសិទ្ធិរបស់សិស្សពិការ និងក្រុមគ្រួសាររបស់ពួកគេដែលស្ថិតនៅក្រោម DDA ។ បទដ្ឋាននេះមានបំណងធ្វើឱ្យវា**កាន់តែងាយស្រួលក្នុងការស្វែងយល់អំពីសិទ្ធិ និងកាតព្វកិច្ចក្រោមDDA។**

បទដ្ឋាននេះបានកំណត់**សិទ្ធិរបស់សិស្សដែលមានពិការភាព** និង**កាតព្វកិច្ចរបស់អ្នកផ្តល់ការអប់រំ**ទាក់ទងទៅនឹង៖

- ការចុះឈ្មោះចូលរៀន
- ការចូលរួម
- ការអភិវឌ្ឍន៍កម្មវិធីសិក្សា ការទទួលស្គាល់ និងការផ្តល់ការអប់រំ
- សេវាកម្មជួយ និងគាំទ្រសិស្សានុសិស្ស និង
- ការលុបបំបាត់ការយាយី ធ្វើបាប និងការរងគ្រោះ។

នៅក្នុងបរិបទការអប់រំ និងការថែរក្សាកុមារតូច**ស្តង់ដារបានអនុវត្តចំពោះ “សាលាមត្តេយ្យរួមទាំងសាលាកុមារតូចៗ (ប៉ុន្តែមិនមែនអ្នកផ្តល់សេវាកម្មថែទាំកុមារ ឬ child-care providersនោះទេ)”**[1]។

នេះមានន័យថាសាលាមត្តេយ្យ (រាប់បញ្ចូលទាំងសាលាកុមារតូចៗ) រួមទាំងកុមារ និងគ្រួសារដែលប្រើប្រាស់សេវាកម្មនេះមានសិទ្ធិ និងកាតព្វកិច្ចរបស់ពួកគេដែលបានចែងក្នុង DDA ដែលបញ្ជាក់ចេញពីបទដ្ឋាននេះ។ អ្នកផ្តល់សេវាថែទាំកុមារ និងក្រុមគ្រួសារដែលប្រើប្រាស់សេវាកម្មរបស់ពួកគេពឹងផ្អែកលើគោលការណ៍ដែលអាចត្រូវបានកំណត់តាមរយៈលទ្ធផលរបស់តុលាការនីមួយៗដើម្បីណែនាំការបកស្រាយអំពីសិទ្ធិ និងកាតព្វកិច្ចរបស់ពួកគេក្រោម DDA ។

ស្តង់ដារទាំងនេះត្រូវបានពិនិត្យឡើងវិញកាលពីឆ្នាំ២០១០ និងឆ្នាំ២០១៥។ ការពិនិត្យឡើងវិញ**ទាំងឆ្នាំ២០១០ និង២០១៥ បានផ្តល់អនុសាសន៍ពិចារណាលើការពង្រីកការអនុវត្តស្តង់ដារនេះដល់អ្នកផ្តល់សេវាថែទាំកុមារ**។ ការពិនិត្យឡើងវិញនៅឆ្នាំ២០១៥ បានរកឃើញថាវិស័យនេះបានឆ្លងកាត់ការកែទម្រង់យ៉ាងសំខាន់ដែលបានសង្កត់ធ្ងន់កាន់តែខ្លាំងឡើងចំពោះគោលបំណងអប់រំនៃការអប់រំ និងការថែរក្សាកុមារតូចៗហើយបានកត់សម្គាល់ថាការមិនរាប់បញ្ចូលការថែទាំកុមារពីបទដ្ឋានហាក់ដូចជាមិនមានលក្ខណៈត្រឹមត្រូវ។

ការពិនិត្យឡើងវិញពីមុនក៏បានរកឃើញភាពខុសគ្នាដែលបានធ្វើឡើងនៅក្នុងបទដ្ឋានរវាងសាលាមត្តេយ្យ / សាសាកុមារតូចៗ និងអ្នកផ្តល់ការថែទាំកុមារដែលមិនឆ្លុះបញ្ចាំងពីការរៀបចំយ៉ាងស្មុគស្មាញដែលមាននៅក្នុងវិស័យអប់រំ និងថែទាំកុមារតូចៗនោះទេ។

- មានសេវាកម្មជា**ច្រើនប្រភេទដែលផ្តល់ដោយអ្នកផ្តល់ការអប់រំនិងថែទាំកុមារតូចៗ។** ទាំងនេះរួមមានសាលាមត្តេយ្យ មណ្ឌលថែទាំពេលថ្ងៃ មជ្ឈមណ្ឌលថែទាំគ្រួសារនៅផ្ទះ មើលថែក្រៅម៉ោងសិក្សា(រាប់បញ្ចូលទាំងក្មេងអាយុចូលរៀន) និងសេវាកម្មផ្សេងៗទៀត។
- **កម្មវិធីអប់រំ និងថែទាំដំបូងរួមទាំងកម្មវិធីមត្តេយ្យត្រូវបានផ្តល់ជូនតាមវិធីផ្សេងៗគ្នា** (ឧទាហរណ៍ សេវាកម្មថែទាំកុមារដែលមានមូលដ្ឋាននៅកណ្តាលអាចផ្តល់ជូនកម្មវិធីសាលាមត្តេយ្យ)។

## ការពិនិត្យឡើងវិញនៃបទដ្ឋានឆ្នាំ២០២០

ជាផ្នែកមួយនៃការពិនិត្យឡើងវិញនៃបទដ្ឋានឆ្នាំ២០២០ ក្រុមការងារយើងកំពុងពិនិត្យមើលវិសាលភាពដែល**ក្រុមគ្រួសារ អ្នកអប់រំ និងអ្នកផ្តល់ការអប់រំ និងថែទាំកុមារតូចៗបានដឹងស្វែងយល់ និងអនុវត្តតាមសិទ្ធិ និងការទទួលខុសត្រូវដែលមានស្រាប់របស់ពួកគេនៅក្រោម DDA ។**

យើងនឹងប្រើប្រាស់ព័ត៍មាននេះដើម្បីជួយយើងក្នុងការកំណត់នូវអ្វីដែលអាចនឹងតម្រូវឱ្យមាន៖

- ជួយឪពុកម្តាយ និងអ្នកថែទាំឱ្យយល់ និងតស៊ូមតិដើម្បីសិទ្ធិកុមារដែលមានពិការភាពរបស់ពួកគេ
- ផ្តល់ឱ្យអ្នកផ្តល់សេវាថែទាំកុមារនូវភាពច្បាស់លាស់ និងកាន់តែច្បាស់អំពីកាតព្វកិច្ចរបស់ពួកគេទាក់ទងនឹងកុមារដែលមានពិការភាព
- គាំទ្រដល់កុមារដែលមានពិការភាពក្នុងការទទួលបានការអប់រំនៅក្នុងកន្លែងថែទាំ និងថែទាំកុមារតូចនៅលើមូលដ្ឋានដូចគ្នាទៅនឹងកុមារដែលគ្មានពិការ។

## តើអាចចូលរួមក្នុងការពិនិត្យឡើងវិញនេះដោយរបៀបណា

យើង**ស្វាគមន៍រាល់មតិយោបល់ពីមនុស្សគ្រប់រូប**ក្នុងការពិនិត្យឡើងវិញនេះ។

[1] *ស្តង់ដារជនពិការសម្រាប់ការអប់រំឆ្នាំ ២០០៥* https://www.legislation.gov.au/Details/F2005L00767

ការពិគ្រោះយោបល់ជាសាធារណៈរបស់យើងសម្រាប់ការអប់រំ
និងការថែទាំកុមារតូចៗនឹងចាប់ផ្តើមពីខែសីហាដល់ ខែកញ្ញាឆ្នាំ២០២០។
យើងផ្តល់ជូននូវវិធីជាច្រើនដើម្បីចូលរួម និងអាចចេញជាមតិបាន។
នេះនឹងរួមបញ្ចូលសិក្ខាសាលាពិសេស
និងក្រុមផ្តោតសំខាន់ទៅលើកុមារដែលមានពិការភាពក្នុងការអប់រំ និងសេវាថែរក្សាកុមារតូចៗ។
នៅពេលកាលបរិច្ឆេទសម្រាប់ការពិគ្រោះយោបល់ត្រូវបានបញ្ជាក់ពួកយើងនឹងចេញផ្សាយនៅក្នុង
គេហទំព័រ របស់យើងខ្ញុំ។

នៅលើមជ្ឈមណ្ឌលពិគ្រោះយោបល់ គេហទំព័ររបស់យើងខ្ញុំ លោកអ្នកអាចសរសេរការសរសេរជាវីដេអូ
ឬ ថតជាសម្លេងផ្ទាល់របស់លោកអ្នក ឬ បំពេញកម្រងសំណួរដែលមានស្រាប់។
លោកអ្នកក៏នឹងមានឱកាសពិគ្រោះយោបល់តាមអ៊ីនធឺណែតជាច្រើនផងដែរដែលអ្នកអាចបង្ហាញ
ពីចំណាប់អារម្មណ៍របស់លោកអ្នកបាន។

ដោយសារតែជំងឺកូវីដ១៩ ការជួបភាគច្រើននឹងជួបជាប្រព័ន្ធអ៊ីនធឺណែត។

ព័ត៌មានបន្ថែម លោកអ្នកអាចចូលក្នុងគេហទំព័រ របស់យើងខ្ញុំ។

## ការពិគ្រោះយោបល់ជាមួយអ្នកផ្តល់ការអប់រំ និងថែទាំកុមារតូចៗ

អាជ្ញាធរគុណភាពអប់រំ និងថែទាំកុមារអូស្ត្រាលី (ACECQA)
គឺជាអាជ្ញាធរជាតិដែលជួយរាជរដ្ឋាភិបាលទាំងអស់ក្នុងការគ្រប់គ្រងក្របខណ្ឌគុណភាពថ្នាក់ជាតិស
ម្រាប់សេវាថែទាំ និងថែទាំកុមារតូចៗ។ ACECQA
នឹងធ្វើការពិគ្រោះយោបល់ជាមួយអ្នកផ្តល់ការអប់រំ
និងថែទាំកុមារតូចៗដើម្បីជូនដំណឹងអំពីការកែសម្រួលនេះឆ្នាំ២០២០ ។

ការពិគ្រោះយោបល់របស់ ACECQA
នឹងស្វែងយល់ពីបញ្ហាជាច្រើននៅក្នុងឯកសារពិភាក្សានេះនិងស្វែងរកទស្សនៈរបស់លោកអ្នក
ដែលបានផ្តល់យោបល់ទៅលើឱកាសផ្សេងទៀតដើម្បីគាំទ្រដល់ការចូលដំណើរការ
និងការចូលរួមរបស់កុមារដែលមានពិការភាពនៅក្នុងការអប់រំ និងការថែទាំកុមារតូចៗ
និងការអប់រំ និងការថែទាំកុមារវ័យ។

ACECQA នឹងទាក់ទងដោយផ្ទាល់ទាក់ទងទៅនឹងការពិនិត្យឡើងវិញនេះ។ សម្រាប់ព័ត៌មានបន្ថែម
លោកអ្នកអាចចូលទៅកាន់គេហទំព័ររបស់ ACECQA។

អ្នកផ្តល់សេវានីមួយៗត្រូវបានស្វាគមន៍ក្នុងការដាក់ស្នើដោយផ្ទាល់ទៅក្នុងការពិនិត្យឡើងវិញ
ឬជំនួសឱ្យការចូលរួមក្នុងការពិគ្រោះយោបល់ដែលដឹកនាំដោយ ACECQA ។

## បញ្ចេញមតិរបស់លោកអ្នក

យើង**ចង់ដឹងអំពីទស្សនៈរបស់លោកអ្នក**។
សំណួរខាងក្រោមនេះជាអ្វីដែលលោកអ្នកត្រូវគិតដើម្បី**ជួយអ្នកក្នុងការផ្តល់យោបល់របស់លោកអ្នក
ក្នុងការពិនិត្យមើលឡើងវិញអំពីបទពិសោធន៍របស់កុមារដែលមានពិការភាព និងឪពុកម្តាយ
និងអ្នកថែទាំពួកគេក្នុងការអប់រំ និងថែទាំកុមារតូចៗ។**

លោកអ្នកអាចឆ្លើយសំណួរដោយធ្វើការដាក់ស្នើឆ្លើយសំណួរ ឬ ចូលរួមតាមមធ្យោបាយផ្សេងៗទៀត។
សំណួរគ្រាន់តែជាការណែនាំដើម្បីជួយឱ្យយើងយល់ពីទស្សនៈ
និងបទពិសោធន៍របស់លោកអ្នកតែប៉ុណ្ណោះ។

នៅពេលផ្តល់ចម្លើយសូមប្រាប់យើងថាតើអ្នកជាឪពុកម្តាយ / អ្នកថែទាំអ្នកអប់រំ អ្នកតស៊ូមតិ ឬ
អ្នកផ្តល់ការអប់រំ និងថែទាំកុមារតូចៗ។
នៅពេលដែលសមរម្យសូមប្រាប់យើងផងដែរថាតើយោបល់របស់អ្នកទាក់ទងនឹងផ្នែកអប់រំ
និងថែទាំកុមារតូចមួយណា ឧទាហរណ៍សាលាមត្តេយ្យ មណ្ឌលថែទាំពេលថ្ងៃ
មជ្ឈមណ្ឌលថែទាំគ្រួសារក្នុងការថែទាំតាមផ្ទះ ការថែទាំក្រៅម៉ោងសិក្សា ឬ
ប្រភេទសេវាកម្មផ្សេងៗទៀត។

# សំណួរសម្រាប់ឪពុកម្តាយ និងអ្នកថែរក្សាកុមារដែលមានពិការភាព

**ប្រាប់យើងអំពីបទពិសោធន៍របស់លោកអ្នកជាមួយនឹងការអប់រំ និងការថែទាំកុមារតូចៗ**

- ការចូលរៀន និងការចូលរួម៖
  តើអ្នកមានបទពិសោធន៍អ្វីខ្លះនៅពេលទទួលបានការអប់រំនិងការមើលថែក្មេងរបស់លោកអ្នក? តើដំណើរការនេះមានដំណើរការយ៉ាងដូចម្តេច ហើយតើលោកអ្នកសប្បាយចិត្តនឹងលទ្ធផលនៃដំណើរការចូលរូមនេះដែរ ឬ ទេ?

- ការចូលរួមចំណែក៖
  តើអ្នកផ្តល់សេវាកម្មរបស់លោកអ្នកបានធ្វើការកែតម្រូវសមហេតុផលដើម្បីធានាថាកូនរបស់លោកអ្នកអាចចូលរួមក្នុងការអប់រំ និងថែទាំកុមារតូចបានទេ? នេះរួមបញ្ចូលទាំងកូនរបស់អ្នកចូលរួមវគ្គសិក្សា ឬ កម្មវិធីកម្មវិធីសិក្សា និងការប្រើប្រាស់សម្ភារៈផ្សេងៗ។ តើអ្នកអប់រំ និងថែទាំកុមារតូចរបស់លោកអ្នកបានពិគ្រោះយោបល់ជាមួយលោកអ្នកយ៉ាងដូចម្តេច? តើលោកអ្នកសប្បាយចិត្តនឹងលទ្ធផលនេះទេ?

- គាំទ្រកុមារដែលមានពិការភាព៖
  តើលោកអ្នកអាចទទួលបានការគាំទ្រសមស្របសម្រាប់កូនរបស់លោកអ្នកពីអ្នកផ្តល់ការអប់រំ និងការថែរក្សាកុមារតូចៗ រួមទាំងការគាំទ្រជំនាញតាមតម្រូវការដែរ ឬ ទេ?

- ការធ្វើបាបនានា៖ ប្រសិនបើលោកអ្នក និង/ឬ កូនរបស់លោកអ្នកជួបប្រទះការយាយី ឬ រងគ្រោះនៅក្នុងកន្លែងអប់រំ និងថែទាំកុមារតូច តើមានអ្វីកើតឡើង? តើអ្នកផ្តល់ការអប់រំនិងការថែទាំកុមារតូចបានចាត់វិធានការអ្វីខ្លះដើម្បីដោះស្រាយបញ្ហានេះដែរ ឬ ទេ?

- ការគោរពទៅតាមគោលការណ៍៖
  ប្រសិនបើលោកអ្នកគិតថាលោកអ្នកផ្តល់ការអប់រំនិងថែទាំកុមារតូចមិនបំពេញកាតព្វកិច្ចរបស់ពួកគេតើត្រូវដោះស្រាយយ៉ាងដូចម្តេច? តើលោកអ្នកដឹងពីរបៀបដាក់ពាក្យបណ្តឹងទេ? តើមានអ្វីកើតឡើង?

- ការផ្លាស់ប្តូរ៖
  លោកអ្នកអាចប្រាប់មកក្រុមការងារយើងអំពីបទពិសោធន៍របស់កូនលោកអ្នកក្នុងការផ្លាស់ប្តូររវាងការអប់រំ និងការថែទាំកុមារតូចៗ និងសាលារៀន។ តើអ្នកផ្តល់ការអប់រំនិងថែទាំកុមារតូចរបស់លោកអ្នកបានចែករំលែកព័ត៌មានជាមួយសាលាដែ រឬ ទេ?

- កូនដែលមានពិការភាពរបស់ជនជាតិដើមAboriginal និង Torres Strait Islander៖
  លោកអ្នកអាចប្រាប់ក្រុមការងារយើងអំពីបទពិសោធន៍របស់កូនលោកអ្នកក្នុងការចូលរៀន និងចូលរួមក្នុងការអប់រំ និងការថែទាំកុមារតូចៗ។ តើលោកអ្នកមានអារម្មណ៍ថាការចូលរួមគឺសមរម្យតាមវប្បធម៌ទេ?

- បទពិសោធន៍ដទៃៗ៖ ការចូលរៀន និងការចូលរួមក្នុងការអប់រំ និងថែទាំកុមារតូចៗអាចត្រូវបានរងផលប៉ះពាល់ដោយកាលៈទេសៈផ្សេងទៀតដូចជាអាយុ ភេទរបស់អ្នក ឬ ភេទនិន្នាការ ឬ ស្ថានភាពភេទ ឬ ដោយសារតែវប្បធម៌ និងភាសាខុសៗគ្នា។ សូមលោកអ្នកប្រាប់មកយើងខ្ញុំអំពីស្ថានភាពរបស់លោកអ្នកដែលជះឥទ្ធិពលដល់ការចូល និងការចូលរួមរបស់កូនលោកអ្នកក្នុងការអប់រំ និងការថែទាំកុមារតូចៗ។

- ជំងឺកូវីដ១៩៖ តើកូនរបស់លោកអ្នកបានជួបប្រទះបញ្ហានានាកំឡុងពេលកូវីដ១៩ដែរ ឬ ទេ? ចុះនៅពេលមានគ្រោះធម្មជាតិ ឬ បញ្ហាអាសន្ននានា?

**ក្រុមការងារយើងចង់យល់ពីអ្វីដែលលោកអ្នកបានដឹងអំពីសិទ្ធិរបស់លោកអ្នក និងកូនរបស់លោកអ្នក**

- តើលោកអ្នកធ្លាប់ស្គាល់ពី DDA ដែរ ឬ ទេ? ប្រសិនជាធ្លាប់ នៅពេលណា?
- តើលោកអ្នកយល់ដឹងពី DDA ដែរ ឬ ទេ?
- តើលោកអ្នកមានអារម្មណ៍ថាលោកអ្នកយល់ពីសិទ្ធិរបស់លោកអ្នក និងកូនរបស់លោកអ្នកដែរ ឬ ទេ ជាពិសេសនៅពេលដែលពួកគេមានលទ្ធភាពចូលរួមក្នុងការអប់រំ និងវិស័យថែទាំកុមារតូចៗ?
- តើ DDA គួរធ្វើដូចម្តេច ដើម្បីឱ្យមានការរីកចម្រើនទៅមុខ?
- តើក្រុមការងារយើងគួរធ្វើដូចម្តេចដើម្បីឱ្យលោកអ្នកស្គាល់ច្បាស់ពីសិទ្ធិរបស់កូនរបស់លោកអ្នក?

## សំណួរសម្រាប់អ្នកផ្តល់សេវាកម្មអប់រំ

**ប្រាប់យើងអំពីបទពិសោធន៍របស់លោកអ្នកជាមួយកូនសិស្សដែលមានពិការភាព**

- <u>ការចូលរៀន និងការចូលរួម៖</u>
  តើអ្នកមានបទពិសោធន៍អ្វីខ្លះជាមួយកុមារដែលមានពិការភាពក្នុងការទទួលបានការអប់រំ និងការថែទាំកុមារតូចៗ?
- <u>ការចូលរួមចំណែក៖</u>
  តើអ្នកយល់ពីកាតព្វកិច្ចរបស់អ្នកក្នុងការធ្វើការកែតម្រូវសមហេតុផលដើម្បីធានាថាកុមារដែលមានពិការភាពអាចចូលរួមក្នុងការអប់រំ និងថែទាំកុមារតូចបានទេ? នេះរួមបញ្ចូលទាំងការចូលរួមក្នុងវគ្គសិក្សានិងកម្មវិធីកម្មវិធីសិក្សា និងការប្រើប្រាស់មធ្យោបាយនានា។ តើអ្នកដឹងពីរបៀបពិគ្រោះជាមួយឪពុកម្តាយ / អ្នកថែទាំទេ? ប្រសិនបើអ្នកមានបទពិសោធន៍ក្នុងការធ្វើការកែតម្រូវសមហេតុផល សូមប្រាប់យើងអំពីបញ្ហានេះ។
- <u>គាំទ្រកុមារដែលមានពិការភាព៖</u>
  តើអ្នកបានជួយកុមារពិការភាពក្នុងកំឡុងពេលសិក្សាយ៉ាងដូចម្តេច? តើអ្នកណាពាក់ព័ន្ធក្នុងការរៀបចំផែនការគាំទ្រនោះ?
- <u>ការគោរពទៅតាមគោលការណ៍៖</u> តើមានកុមារណាម្នាក់ក្នុងការមើលថែរបស់អ្នក ឪពុកម្តាយ / អ្នកថែទាំបាននិយាយថាអ្នកមិនបានបំពេញកាតព្វកិច្ចរបស់អ្នកហើយ ឬ នៅ? តើអ្នកបានដោះស្រាយបញ្ហានេះដោយរបៀបណា?
- <u>ការផ្លាស់ប្តូរ៖</u>
  សូមលោកអ្នកប្រាប់យើងអំពីបទពិសោធន៍របស់អ្នកក្នុងការជួយកុមារដែលមានពិការភាពក្នុងការផ្លាស់ប្តូរពីការអប់រំ និងការថែរក្សាកុមារតូចៗទៅសាលារៀន។
- <u>កូនដែលមានពិការភាពរបស់ជនជាតិដើមAboriginal និង Torres Strait Islander៖</u>
  សូមលោកអ្នកប្រាប់យើងអំពីបទពិសោធន៍របស់លោកអ្នកក្នុងការជួយដល់កុមារដែលមានពិការភាពដែលជាជនជាតិដើម Aboriginal និង Torres Strait Islander។ តើអ្នកជួយពួកគេឱ្យចូល និងចូលរួមក្នុងការអប់រំយ៉ាងដូចម្តេច? តើអ្នកពិគ្រោះយោបល់ជាមួយពួកគេ និងក្រុមគ្រួសារ និងអ្នកថែទាំរបស់ពួកគេយ៉ាងដូចម្តេច? តើអ្នកមានអារម្មណ៍ថាអ្នកមានកម្រិតវប្បធម៌គ្រប់គ្រាន់ដើម្បីចូលរួមក្នុងវប្បធម៌ដែលសមស្របខាងលើដែរ ឬ ទេ?
- <u>បទពិសោធន៍ដទៃៗ៖</u> ការចូលរៀន និងការចូលរួមក្នុងការអប់រំ និងថែទាំកុមារតូចៗអាចត្រូវបានរងផលប៉ះពាល់ដោយកាលៈទេសៈផ្សេងទៀតដូចជាអាយុ

ភេទរបស់អ្នក ឬ ភេទនិន្នាការ ឬ ស្ថានភាពភេទ ឬ ដោយសារតែវប្បធម៌ និងភាសាខុសៗគ្នា។ ប្រសិនបើអ្នកមានបទពិសោធន៍ជាមួយកុមារ ឬ ឪពុកម្តាយនិងអ្នកមើលថែដែលរងផលប៉ះពាល់ដោយកាលៈទេសៈផ្សេងទៀត សូមលោកអ្នកប្រាប់យើងអំពីវិធីដែលលោកអ្នកបានជួយកូនរបស់ពួកគេឱ្យទទួលបាន និងចូលរួមក្នុងការអប់រំ និងការថែទាំកុមារតូចៗទាំងនោះ។

- <u>ជំងឺកូវីដ១៩៖</u><br>តើសិស្សានុសិស្សរបស់លោកអ្នកបានជួបប្រទះបញ្ហានានាកំឡុងពេលកូវីដ១៩ដែរ ឬ ទេ? ចុះនៅពេលមានគ្រោះធម្មជាតិ ឬ បញ្ហាអាសន្ននានា?

**ក្រុមការងារយើងចង់ដឹងអំពីអ្វីដែលលោកអ្នកបានស្គាល់ និងយល់ពីកាតព្វកិច្ចរបស់លោកអ្នក**

- តើលោកអ្នកធ្លាប់ស្គាល់ពី DDA ដែរ ឬ ទេ? ប្រសិនជាធ្លាប់ នៅពេលណា?
- តើលោកអ្នកយល់ដឹងពី DDA ដែរ ឬ ទេ?
- តើលោកអ្នកបានទទួល ឬ ផ្តល់នូវការបណ្តុះបណ្តាលប្រភេទណាមួយនៅលើ DDA ដែរឬ ទេ? តើនេះរួមបញ្ចូលអ្វីខ្លះ?
- តើលោកអ្នកយល់ពីកាតព្វកិច្ចរបស់លោកអ្នកដែរ ឬ ទេ នៅពេលនិយាយដល់កុមារដែលមានពិការភាពអាចចូលរួមក្នុងការអប់រំ និងថែទាំកុមារតូច?
- តើអ្នកផ្តល់សេវាថែទាំ និងអ្នកថែទាំ / អ្នកមើលថែក្មេងរបស់លោកអ្នកអាចជួយលោកអ្នកឱ្យបំពេញកាតព្វកិច្ចរបស់លោកអ្នកដែលស្ថិតនៅក្រោមច្បាប់ DDA យ៉ាងដូចម្តេចដែរ?
- តើលោកអ្នកមានអារម្មណ៍ថាមានទំនុកចិត្តក្នុងការចរចា និងអនុវត្តការកែតម្រូវសមហេតុផលដែរ ឬ ទេ? តើអ្នកដឹងពីវិធីដើម្បីកំណត់ថាតើបញ្ហានេះនឹងនាំឱ្យមានការលំបាកដែលមិនសមហេតុផលដែរ ឬ ទេ?
- តើ DDA គួរធ្វើដូចម្តេច ដើម្បីឱ្យមានការរីកចម្រើនទៅមុខ?
- តើក្រុមការងារយើងគួរធ្វើដូចម្តេចដើម្បីឱ្យលោកអ្នកស្គាល់ច្បាស់ពីសិទ្ធិរបស់លោកអ្នក និងសិស្សានុសិស្សរបស់លោកអ្នក?

## ភាពងាយស្រួល

ដើម្បីជួយធានាថាជនពិការអាចចូលរួមជាមួយការពិនិត្យឡើងវិញ និងចែករំលែកការយល់ដឹង និងបទពិសោធន៍របស់ពួកគេបាន ពួកគេអាចចូលរួមការពិគ្រោះយោបល់ដោយមានឯកសារងាយស្រួលអាន អ្នកបកប្រែភាសាអង់គ្លេស អ្នកបកប្រែភាសាគរ និងមានចំណងជើង។ ភាពងាយស្រួលអាន និងសម្ភារៈផ្សេងទៀតនឹងត្រូវបានផ្តល់ជូនជាមុនដើម្បីជួយអ្នកចូលរួមទទួលបានព័ត៌មានដែលត្រឹមត្រូវរួមទាំងសំណួរដែលត្រូវបានសួរ។ ការពិនិត្យឡើងវិញនឹងពិចារណាទៅលើចំណូលចិត្តរបស់ប្រជាជនអំពីវិធីដែលពួកគេចង់ចែករំលែកបទពិសោធន៍របស់ពួកគេ។ អ្នកចូលរួមអាចជ្រើសរើសវិធីដែលពួកគេចង់ចូលរួមរួមមានការឆ្លើយសំណួរតាមពេលវេលាផ្ទាល់ខ្លួនតាមប្រព័ន្ធអ៊ីនធឺណែត ឬ ចូលរួមការពិភាក្សាដោយផ្ទាល់។ យើងនឹងខិតខំឱ្យអស់ពីលទ្ធភាពដើម្បីធានាបាននូវឱកាសរួមទាំងរយៈពេល និងការពិគ្រោះយោបល់ដែលសមស្របនឹងតម្រូវការ និងសំណូមពរជាក់លាក់របស់ប្រជាពលរដ្ឋ។

## ការចូលរួមទាំងអស់នោះនឹងជួយឱ្យក្រុមការងារយើងខ្ញុំរៀបចំសំណុំរឿងទៅរាជរដ្ឋាភិបាល

ការចូលរួមរបស់លោកអ្នកទៅការពិនិត្យឡើងវិញនឹងផ្តល់នូវការយល់ដឹងអំពីរបៀបដែលសេវាកម្មនិងក្រុមគ្រួសារយល់ច្បាស់អំពីសិទ្ធិ និងកាតព្វកិច្ចរបស់ពួកគេក្រោមDDA ទាក់ទងនឹងការអប់រំនិងការរៀនសូត្រដែលបានផ្តល់ឱ្យនៅក្នុងកន្លែងអប់រំ និងថែទាំកុមារតូច។ ប្រសិនបើយើងឃើញថាការរៀបចំបច្ចុប្បន្នមិនដំណើរការល្អយើងនឹងផ្តល់អនុសាសន៍លើអ្វីដែលត្រូវការផ្លាស់ប្តូររបៀបផ្លាស់ប្តូរវាហើយក្នុងពេលណាដែលការផ្លាស់ប្តូរក្របខណ្ឌគួរតែត្រូវបានអនុវត្ត។

ក្រុមការងារយើងនឹងធ្វើកិច្ចការនេះក្នុងភាពជាដៃគូជាមួយរាជរដ្ឋាភិបាលតំបន់ និងរដ្ឋដែលយើងនឹងធ្វើការយ៉ាងជិតស្និទ្ធ និងសហការដើម្បីអភិវឌ្ឍរបាយការណ៍ចុងក្រោយ និងអនុសាសន៍ទាក់ទងនឹងរបាយការណ៍។ គោលបំណងរបស់យើងគឺផ្តោតសំខាន់ទៅលើឱកាសសម្រាប់សកម្មភាពសហប្រតិបត្តិការថ្នាក់ជាតិរវាងរដ្ឋាភិបាលអូស្ត្រាលីថ្នាក់ជាតិ រដ្ឋ ជាមួយនឹងរាជរដ្ឋាភិបាលថ្នាក់ក្រោម និងអ្នកផ្តល់ការអប់រំដែលមិនមែនជារបស់រាជរដ្ឋាភិបាល។

ការពិនិត្យកែសម្រួលនេះនឹងធ្វើជារបាយការណ៍ផ្ញើជូនរដ្ឋមន្ត្រីក្រសួងអប់រំនៅខែធ្នូ ឆ្នាំ២០២០។ របាយការណ៍ចុងក្រោយនឹងរៀបចំបញ្ជូនទៅគណៈរដ្ឋមន្ត្រីនៅដើមឆ្នាំ២០២០។

## ការរៀបចំចូលរួមបញ្ចេញមតិ

ប្រជាពលរដ្ឋ និងអង្គការនានាអាចបញ្ចេញមតិបាននៅក្នុង [គេហទំព័ររបស់យើងខ្ញុំ]។

ការបញ្ចេញមតិអាចជាការសរសេរ ថតជាវីដេអូ ឬ សម្លេង ឬ បំពេញចម្លើយនៃសំណួរនៅក្នុងគេហទំព័ររបស់យើង។ ការសរសេរបំពេញចម្លើយកំណត់ត្រឹមតែ ៣០០០ ពាក្យប៉ុណ្ណោះ។

ប្រសិនជាការបញ្ចេញមតិទាំងអស់មិនអាចផ្ញើមកយើងខ្ញុំជាក្នុងគេហទំព័របានទេ លោកអ្នកអាចផ្ញើមកកាន់អាសយដ្ឋានៈ

Disability Standards for Education Review Team
Disability Strategy Taskforce
GPO Box 9880
Canberra City ACT 2601

## សម្រាប់ព័ត៌មានបន្ថែម

សម្រាប់ព័ត៌មានទាក់ទងនឹងការបញ្ចេញមតិ សូមលោកអ្នកទាក់ទងមកកាន់ ក្រសួងអប់រំ ជំនាញ និងការងារថ្នាក់ជាតិ តាមរយៈអ៊ីម៉ែលៈ DisabilityStrategy@dese.gov.au។

សម្រាប់ព័ត៌មានទាក់ទងនឹងការចូលរួម ដូចជាជំនួយបញ្ហាបច្ចេកទេសនានា លោកអ្នកអាចទាក់ទងមកកាន់អ៊ីម៉ែល engage@thesocialdeck.com ឬ ទូរស័ព្ទលេខ 0491 617 118។